# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០៣៤ គ.ជ.ប.ស.ជ.៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្តូរការិយាល័យបោះឆ្នោតរបស់បេក្ខជន សហព័ទ្ធ និងកូនរបស់បេក្ខជន សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)** សូមជូនដំណឹងដល់គ្រប់គណបក្សនយោបាយ និងបេក្ខជន ដែលត្រូវបានអនុម័តយល់ព្រមឱ្យចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដោយ គ.ជ.ប អំពីការស្នើសុំប្តូរការិយាល័យបោះឆ្នោតរបស់បេក្ខជន សហព័ទ្ធ និងកូនរបស់បេក្ខជន ដូចខាងក្រោម ៖

១- អនុលោមតាមមាត្រា ៨៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បេក្ខជនឈរឈ្មោះបោះឆ្នោត ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន ដែលបានចុះឈ្មោះបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងមណ្ឌលបោះឆ្នោតផ្សេងពីមណ្ឌលដែលបេក្ខជនឈរឈ្មោះ អាចធ្វើសេចក្តីស្នើសុំមក គ.ជ.ប ឱ្យផ្ទេរឈ្មោះរបស់ខ្លួន ព្រមទាំងសហព័ទ្ធ និងកូន (ក្នុងករណីមានការយល់ព្រមពីសហព័ទ្ធ និងកូន) ទៅកាន់ការិយាល័យបោះឆ្នោតណាមួយក្នុងមណ្ឌលបោះឆ្នោតដែលបេក្ខជននោះឈរឈ្មោះ ។

២- គណបក្សនយោបាយអាចធ្វើពាក្យស្នើសុំជារួមមក គ.ជ.ប ឬបេក្ខជនឈរឈ្មោះបោះឆ្នោតអាចធ្វើពាក្យស្នើសុំផ្ទាល់មក គ.ជ.ប ក៏បាន តាមគំរូទម្រង់ដែលផ្តល់ជូនដោយ គ.ជ.ប ។

៣- ការស្នើសុំប្តូរការិយាល័យបោះឆ្នោត ត្រូវធ្វើនៅការិយាល័យកិច្ចការគណបក្សនយោបាយ និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ទីស្តីការ គ.ជ.ប ជាន់ទី៩ ចាប់ពីថ្ងៃដែល គ.ជ.ប អនុម័តយល់ព្រមឱ្យចុះបញ្ជីឈរឈ្មោះ **រហូតដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣** ជាកំហិត ។ ប្រសិនបើហួសកាលបរិច្ឆេទកំណត់នេះ គ.ជ.ប មិនទទួលខុសត្រូវក្នុងការផ្ទេរឈ្មោះបោះឆ្នោតរបស់បេក្ខជន សហព័ទ្ធ និងកូនឡើយ ។

៤- ពាក្យស្នើសុំ ត្រូវភ្ជាប់មកជាមួយនូវ ៖

- បញ្ជីរាយនាមបេក្ខជន សហព័ទ្ធ និងកូន ដែលត្រូវសុំផ្ទេរឈ្មោះចូលក្នុងការិយាល័យបោះឆ្នោតណាមួយក្នុងមណ្ឌលឈរឈ្មោះរបស់បេក្ខជន ដោយត្រូវបញ្ជាក់ឱ្យច្បាស់អំពីឈ្មោះ និងលេខកូដឃុំ សង្កាត់ លេខកូដ និងឈ្មោះទីតាំងនៃការិយាល័យបោះឆ្នោតដើម និងការិយាល័យបោះឆ្នោតដែលត្រូវផ្ទេរទៅ ។
- លិខិតរបស់សហព័ទ្ធ និងកូន ដែលមានចុះហត្ថលេខា ឬស្នាមមេដៃបញ្ជាក់យល់ព្រមទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោតដែលបេក្ខជនត្រូវឈរឈ្មោះ ។



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh

- ច្បាប់ចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (សម្រាប់សហព័ទ្ធ) ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (សម្រាប់កូន) របស់សាមីបេក្ខជន ។

គ.ជ.ប សង្ឃឹមទុកជាមុនថា គ្រប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នឹងអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ថ្ងៃពុធ ៧កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

សូមស្កេន QR Code

ដើម្បីទាញយកទម្រង់ពាក្យស្នើសុំ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំផ្ទេរឈ្មោះបោះឆ្នោតរបស់បេក្ខជន សហព័ទ្ធ និងកូន

ខ្ញុំបាទ/នាងខ្ញុំ.....................................................................................ភេទ.......................
ថ្ងៃខែឆ្នាំកំណើត.................................សញ្ជាតិ.....................។

ជាបេក្ខជនឈរឈ្មោះបោះឆ្នោតនៅមណ្ឌល...........................................................
របស់គណបក្ស.................................................។

**សូមគោរពជូន**
**ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**កម្មវត្ថុ** : សំណើសុំផ្ទេរឈ្មោះបោះឆ្នោតរបស់បេក្ខជន សហព័ទ្ធ និងកូន សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

**យោង** : - មាត្រា ៩៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។
- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតនៅមណ្ឌល.......................................មានកិត្តិយស សូមជម្រាបជូន **ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំ ព្រមទាំងសហព័ទ្ធ និងកូន មានបំណងផ្ទេរឈ្មោះបោះឆ្នោត ទៅការិយាល័យបោះឆ្នោតក្នុងមណ្ឌល ........................ ដែលខ្ញុំបាទ/នាងខ្ញុំឈរឈ្មោះបោះឆ្នោត (ដូចមានបញ្ជីឈ្មោះបេក្ខជន សហព័ទ្ធ និងកូនជូនភ្ជាប់មកជាមួយ)។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមប្រធាន គ.ជ.ប** មេត្តាពិនិត្យ និងអនុញ្ញាតតាមការគួរ។

សូម **ឯកឧត្តមប្រធាន គ.ជ.ប** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃ..........................ខែ...............ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦......
.........................ថ្ងៃទី.........ខែ.................ឆ្នាំ២០២៣

**ហត្ថលេខា និងឈ្មោះសាមីខ្លួន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រូបសញ្ញា

**គណបក្ស**.............................................
លេខ.............................

## ពាក្យសុំផ្ទេរឈ្មោះបោះឆ្នោតរបស់បេក្ខជន សហព័ន្ធ និងកូន

គណបក្ស................................................................(អក្សរកាត់)........................................

អក្សរឡាតាំង................................................................(អក្សរកាត់)........................................

## សូមគោរពជូន
## ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**កម្មវត្ថុ** : សំណើសុំផ្ទេរឈ្មោះបោះឆ្នោតរបស់បេក្ខជន សហព័ទ្ធ និងកូន សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

**យោង** : - មាត្រា ៩៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។
- បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។

សេចក្តីមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ គណបក្ស.................................................................. មានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) មេត្តាជ្រាបថា បេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្ស........................................មានបំណងផ្ទេរឈ្មោះបោះឆ្នោតរបស់ខ្លួន ព្រមទាំងសហព័ទ្ធ និងកូន ទៅការិយាល័យបោះឆ្នោតក្នុងមណ្ឌលដែលខ្លួនឈរឈ្មោះ (ដូចមានបញ្ជីឈ្មោះបេក្ខជន សហព័ទ្ធ និងកូនជូនភ្ជាប់មកជាមួយ)។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមប្រធាន គ.ជ.ប** មេត្តាពិនិត្យ និងអនុញ្ញាតតាមការគួរ។

សូម **ឯកឧត្តមប្រធាន គ.ជ.ប** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃ............................ខែ..................ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦......

......................ថ្ងៃទី.........ខែ..............ឆ្នាំ២០២៣

**ប្រធាន ឬតំណាង**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### បញ្ជីឈ្មោះបេក្ខជន សហព័ទ្ធ និងកូនដែលស្នើសុំទៅបោះឆ្នោតនៅមណ្ឌលរាជធានី ខេត្ត..............................................

| លេខ អ.ខ ឬ ឯ.អ | នាមត្រកូល | នាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | បេក្ខជន ឬសហព័ទ្ធ ឬកូន | ល.រ ក្នុងបញ្ជី | ការិយាល័យបោះឆ្នោតដើម | | | ការិយាល័យដែលត្រូវបោះឆ្នោត | | | ហត្ថលេខា បេក្ខជន សហព័ទ្ធ និង កូន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | កូដ រាជធានី ខេត្ត | កូដ ឃុំ សង្កាត់ | កូដ ការិយាល័យ | កូដ រាជធានី ខេត្ត | កូដ ឃុំ សង្កាត់ | កូដ ការិយាល័យ | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

ថ្ងៃ.................................ខែ.................ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦......

........................ថ្ងៃទី............ខែ..............ឆ្នាំ២០២៣

ប្រធានគណបក្ស ឬតំណាង ឬបេក្ខជន